WUML 03/26/06,
Hepatitis B
ជម្ងឺថ្លើមប្រភេទ បេ

ជម្ងឺថ្លើមប្រភេទ បេ គឺកើតឡើងដោយការប៉ះពាល់ជាមួយ វីរុសថ្លើមប្រភេទ បេ។ ជម្ងឺថ្លើមប្រភេទ បេ គឺជាជម្ងឺមួយងាយឆ្លងបំផុត ដោយការបះពាល់ជាមួយនឹងវីរុសថ្លើម A,B,C និង E ។
ទោះជាយ៉ាងណាក៏ដោយជម្ងឺថ្លើមបណ្តាលមកពីបញ្ហារផ្សេងទៀតដូចជា: ពិសារស្រារយះពេលយូរ,មានការប៉ះពាល់ជាមួយជាតិគីមី និងការប្រើថ្នាំមួយចំនួនដែលធ្វើអោយខូចថ្លើម។
គ្រប់ប្រភេទនៃជម្ងឺថ្លើម A,B,C និង E គឺបណ្តាលអោយខូចសាច់ថ្លើម,ហើមថ្លើមនឹងរឹងថ្លើម(Liver Inflamation) ឬអាចបណ្តាលអោយខូចថ្លើមរហូតតែម្តង។

ជម្ងឺថ្លើមប្រភេទ បេ អាចកើតឡើងក្នុងរយះពេលខ្លី,កើតឡើងភ្លាម ឬរយះពេលយូររាំរ៉ៃ។
ការកើតឡើងភ្លាមជាធម្មតាជាសះស្បើយដោយខ្លួនឯងដោយមិនបាច់ព្យាបាល។ចំពោះមនុស្សមួយចំនួនមិនមានអាការះអ្វីឡើយ។ ចំពោះមនុស្សមួយចំនួនទៀតដែលមានអាការះរោគ ជម្ងឺនិងបានធូស្រាលក្នុងរយះពេល ២ ទៅ ៣ សប្តា្ត។ ប៉ុន្តែ អាការះរោគនិងកើតឡើងវិញបន្ទាប់ពី ៤ ទៅ ៨ សប្តា្ត។ អ្នកដែរកើតជម្ងឺថ្លើមភ្លាមហើយបាត់ទៅវិញនោះ អ្នកនោះនិងមិនតើកជម្ងឺថើមទៀតទេ ផងដែរក្នុងខ្លួនរបស់អ្នកបានបង្កើតអង្គបដិបក្ខការពារទប់ទល់នឹងជម្ងឺថ្លើមប្រភេទ បេ ដែរការពារជីវិតរបស់អ្នកទៅថ្ងៃអនាគត។ មនុស្សភាគច្រើនដែលមានជម្ងឺថ្លើមប្រភេទ បេកើតឡើងភ្លាម គឺមិនបណ្តាលកើតជម្ងឺថ្លើមប្រភេទ បេ រាំរ៉ៃទេ។

ជម្ងឺថ្លើមរាំរ៉ៃគឺកើតឡើងនៅពេលដែរមេរោគវីរុសថ្លើមនៅតែបង្ហាញអោយឃើញនៅក្នុងថ្លើម និង ថ្លើមរយះពេល៦ខែ ឬ ច្រើនជាងនេះ។ ជម្ងឺរាំរ៉ៃគឺអាចបណ្តាលអោយមហារីកថ្លើម។ នៅពេលដែលអ្នកមានជម្ងឺថ្លើមប្រភេទ បេ រាំរ៉ៃអ្នកអាចចម្លងមេរោកនេះទៅអ្នកផ្សេងយ៉ាងងាយស្រួល។
ក្នុងការប៉ាន់ប្រមាណមនុស្សប្រមាណ ១២៥ លាននាក់ក្នុងសហរដ្ឋអាមេរិកមាន

ជម្ងឺថ្លើមប្រភេទ បេ រាំរ៉ៃ។ នៅក្នុងសហរដ្ឋអាមេរិកជម្ងឺថ្លើមប្រភេទ បេ កើតឡើងភ្លាម គឺភាគច្រើនកើតឡើងចំពោះក្មេងជំទង់ និង មនុស្សពេញវ័យ។

អាការះនៃជម្ងឺថ្លើមប្រភេទ បេ មាន:

- អស់កម្លាំងល្ហិតល្ហៃ
- គ្រុនក្តៅល្មម
- ឈឺក្បាល
- បរិភោគមិនបាន
- ចង្អោ និង ក្អួត
- កន្ទួលក្រហមលើស្បែក
- ឈឺសាច់ដុំ និង សន្លាក់
- រាគ ឬ ទល់លាមក
- ភ្នែក និងស្បែកឡើងលឿង

មនុស្សភាគច្រើនដែរលាមជម្ងឺថ្លើមរាំរ៉ៃមិនមានអាការះរោគអ្វីឡើយ។

ពត៌មាននេះដកស្រង់ ពី វេបសៃរបស់ Yahoo Health.